# III ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

ភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

### សេចក្ដីសំរេចលេខ ០០១ សសរ .កហវ
### ស្ដីពីការផ្ទេរភារកិច្ចគ្រប់គ្រងប្រមូលពន្ធអាជីវកម្មចល័ត

- បានឃើញព្រះរាជក្រឹត្យរបស់សម្ដេចព្រះ ឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជាចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា។
- បានឃើញលិខិតលេខ ១៨៧ សជណ.ពហ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៣ របស់ ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីវិធានការកែលំអប្រព័ន្ធគយ និង រដ្ឋាករ ។

**សំរេច**

**ប្រការ ១ :** ផ្ទេរភារកិច្ចគ្រប់គ្រងប្រមូលពន្ធ អាជីវកម្មចល័ត ពីនាយកដ្ឋានពន្ធដារ ឧស្សាហកាណិជ្ជប្រគល់ជូន ទៅ ទីចាត់ការគយ - រដ្ឋាករវិញ ។

**ប្រការ ២ :** នាយកដ្ឋានពន្ធដារឧស្សាហកាណិជ្ជ ទីចាត់ការគយ - រដ្ឋាករៈនាយកដ្ឋានចាត់តាំងមន្ទីរ មានភារកិច្ចអនុវត្តតាម សេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ។

**ប្រការ ៣ :** សេចក្ដីសំរេចនេះមានប្រសិទ្ធភាពអនុវត្តជាធរមានចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៣ តទៅ ។

**រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

• • • •